**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០៤០/២៣ ក.ប/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ

## ស្តីពី

## ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល

យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីរក្សាលំនឹងជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិត និងធានានូវស្ថិរភាពអាជីវកម្មរបស់រោងចក្រដែលមានការថមថយប្រវាក់ផលិតកម្មក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចសកល ក្រសួងសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រត្រូវធ្វើការពិភាក្សាគ្នាជាមួយតំណាងបងប្អូនកម្មករនិយោជិត ដើម្បីកំណត់ការផ្លាស់វេនគ្នាធ្វើការងារនៅពេលមានការព្យួរកិច្ចសន្យាការងារក្នុងរយៈពេលកំណត់ណាមួយ ដោយផ្អែកលើគោលការណ៍សមភាព។ បងប្អូនកម្មករនិយោជិត ដែលត្រូវបានព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ នឹងត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចខាងក្រោម៖

- ចំនួន ២០ដុល្លារអាម៉េរិក ពីរាជរដ្ឋាភិបាល និងចំនួន ១៥ដុល្លារអាម៉េរិក ពីនិយោជក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ទៅ ១៤ថ្ងៃ
- ចំនួន ៤០ដុល្លារអាម៉េរិក ពីរាជរដ្ឋាភិបាល និងចំនួន ៣០ដុល្លារអាម៉េរិក ពីនិយោជក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ទៅ ១ខែ។

ដើម្បីទទួលបានប្រាក់ឧបត្ថម្ភនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដូចតទៅ៖

១. ម្ចាស់ ឬនាយករោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប ត្រូវ៖

- ដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានយ៉ាងតិច ៥ថ្ងៃ នៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទនៃការចាប់ផ្តើមព្យួរកិច្ចសន្យាការងារ តាមទម្រង់លិខិតដូចមានក្នុង**ឧបសម្ព័ន្ធទី១** តាមរយៈគេហទំព័រ https://suspension.mlvt.gov.kh ដែលមានសេចក្តីណែនាំអំពីរបៀបប្រើប្រាស់ប្រព័ន្ធនេះដូចមានក្នុង**ឧបសម្ព័ន្ធទី២** នៃសេចក្តីណែនាំនេះ។ រយៈពេលព្យួរកិច្ចសន្យាការងារជាអតិបរមាមានចំនួន ២ខែ និងអាចពន្យារបន្ថែម ក្នុងករណីចាំបាច់ និងស្ថានភាពជាក់ស្តែងក្រោយពីមានការត្រួតពិនិត្យនិងអនុញ្ញាតដោយអធិការការងារ
- ផ្សព្វផ្សាយ និងជូនដំណឹងឱ្យបានទូលំទូលាយ និងជាចំហដល់បងប្អូនកម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារអំពីកាតព្វកិច្ចផ្តល់ជាដាច់ខាតនូវ (១) លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង(២) លេខទូរសព្ទផ្ទាល់ខ្លួន (ឬ លេខទូរសព្ទរបស់ប្តី ប្រពន្ធ កូន ឪពុក ម្តាយ ឬបងប្អូនបង្កើត) ដើម្បីក្រសួងយកទៅធ្វើជាមូលដ្ឋានសម្រាប់ផ្ទេរប្រាក់ឧបត្ថម្ភ តាមរយៈធនាគារឯកទេសវីង ស្របតាមរយៈពេលនៃការព្យួរកិច្ចសន្យាការងារ

- រៀបចំបញ្ជីរាយនាមកម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវតាមទម្រង់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃសេចក្តីណែនាំនេះ ដោយតម្រូវឱ្យសាមីកម្មករនិយោជិតផ្តិតមេដៃនៅលើឈ្មោះរបស់ខ្លួនដើម្បីបញ្ជាក់ថា លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរសព្ទដែលរោងចក្របានរៀបចំនេះ គឺពិតជាត្រឹមត្រូវប្រាកដមែន
- ភ្ជាប់មកជាដាច់ខាតនូវច្បាប់ថតចម្លងឯកសារនីមួយៗចំនួន ២ច្បាប់ រួមមាន (១) បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយ មុនពេលព្យួរកិច្ចសន្យាការងារដោយមានបោះត្រារបស់រោងចក្រនៅគ្រប់ទំព័រ (២) វិញ្ញាបនបត្រពាណិជ្ជកម្ម (៣) បណ្ណពន្ធប៉ាតង់ (៤) វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថានក្នុង ប.ស.ស. និង (៥) លេខគណនីធនាគាររបស់រោងចក្រ
- ក្នុងករណីត្រូវបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការងារវិញ) មុនកាលកំណត់ ដែលមានចែងនៅក្នុងលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ ត្រូវធ្វើលិខិតជូនដំណឹងមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការវិញ តាមទម្រង់លិខិតដូចមានក្នុងឧបសម្ព័ន្ធទី៤ នៃសេចក្តីណែនាំនេះ
- ទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាននូវរាល់ព័ត៌មាន ដែលបានផ្តល់មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវសងជូនរាជរដ្ឋាភិបាលវិញចំពោះការឃុបឃិតក្លែងបន្លំព័ត៌មានណាមួយ ក្នុងការទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារនិងទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល។

ម្ចាស់ ឬនាយករោងចក្រ ដែលខកខានក្នុងការផ្សព្វផ្សាយជាចំហដល់បងប្អូនកម្មករនិយោជិតជ្រាបអំពីតម្រូវការព័ត៌មានខាងលើនេះ ឬខកខានក្នុងការឱ្យបងប្អូនកម្មករនិយោជិតផ្តិតមេដៃ ទទួលស្គាល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរសព្ទ ដែលខ្លួនបានចងក្រងរួចនោះ ត្រូវទទួលខុសត្រូវបង់ជូនបងប្អូនកម្មករនិយោជិតនោះនូវប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល។

ក្នុងអំឡុងពេល ២ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយទទួលបានលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ ដោយមានឯកសារយោងគ្រប់គ្រាន់ អធិការការងារអាចនឹងចុះទៅពិនិត្យ និងផ្ទៀងផ្ទាត់នៅតាមរោងចក្រ។

២. បងប្អូនកម្មករនិយោជិត ត្រូវ៖

- ផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរសព្ទផ្ទាល់ខ្លួន ដែលអាចទាក់ទងបានជូនដល់ម្ចាស់ ឬនាយករោងចក្រ ដែលខ្លួនកំពុងបំពេញការងារ ដើម្បីចងក្រងជាបញ្ជីផ្តល់ជូនក្រសួងយកទៅរៀបចំនីតិវិធីបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលតាមរយៈធនាគារឯកទេសវីង។ ប្រសិនបើគ្មានលេខទូរសព្ទផ្ទាល់ខ្លួន ត្រូវផ្តល់លេខទូរសព្ទជារបស់ប្តី ប្រពន្ធ កូន ឪពុក ម្តាយ ឬបងប្អូនបង្កើត និងមិនត្រូវផ្លាស់ប្តូរលេខទូរសព្ទជាដាច់ខាត
- ពិនិត្យសារតាមទូរសព្ទ ដែលនឹងត្រូវផ្ញើជូនដោយធនាគារឯកទេសវីង ក្នុងអំឡុងពេល ១០ថ្ងៃក្រោយពេលព្យួរកិច្ចសន្យាការងារអំពីទីកប្រាក់ឧបត្ថម្ភដោយរាជរដ្ឋាភិបាល
- យកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅភ្នាក់ងារវីងណាមួយ ដែលនៅជិតផ្ទះបំផុត ដើម្បីបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលនោះ ក្រោយទទួលបានសារជូនដំណឹងតាមទូរសព្ទ។ ធនាគារឯកទេសវីង នឹងបង្វិលថវិកានោះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាកម្មករនិយោជិតណាម្នាក់ខកខានទៅបើកប្រាក់ឧបត្ថម្ភនោះក្នុងរយៈពេល ១០ថ្ងៃ ក្រោយពីធនាគារឯកទេសវីង បានផ្ញើសារតាមទូរសព្ទជូនបងប្អូនកម្មករនិយោជិតរួចហើយ។

ក្រសួងសូមរំលឹកដល់បងប្អូនកម្មករនិយោជិតត្រូវសហការផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរសព្ទ ដែលអាចទំនាក់ទំនងបានទៅរោងចក្រជាដាច់ខាត ព្រមទាំងត្រូវពិនិត្យលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរសព្ទ ដែលមាននៅក្នុងតារាងបញ្ជីឈ្មោះកម្មករនិយោជិតត្រូវព្យួរកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវ មុននឹងផ្តិតមេដៃបញ្ជាក់អំពីភាពត្រឹមត្រូវនៃព័ត៌មានទាំងពីរនេះ។

បងប្អូនកម្មករនិយោជិតណាម្នាក់ ដែលខកខានក្នុងការផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរសព្ទដល់រោងចក្រ គឺមានន័យថាសាមីខ្លួនបានស្ម័គ្រចិត្តមិនទទួលយកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល។

៣. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រោយពីបានផ្តល់ការអនុញ្ញាតព្យួរកិច្ចសន្យាការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចម្លងលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ តាមទម្រង់លិខិតដូចមានក្នុងឧបសម្ព័ន្ធទី៥ នៃសេចក្តីណែនាំនេះដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលរាជធានី ខេត្ត ដែលពាក់ព័ន្ធ។

ក្រសួងសូមបញ្ជាក់ថា ការផ្តល់ប្រាក់ឧបត្ថម្ភព្យួរកិច្ចសន្យាការងារ នឹងត្រូវអនុវត្តសម្រាប់រោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលទទួលបានការអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ តទៅ។ ដោយឡែក ការព្យួរកិច្ចសន្យាការងារដែលបានអនុវត្តមុនថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ត្រូវអនុវត្តតាមការព្រមព្រៀងគ្នារវាងភាគីនិយោជក និងបងប្អូនកម្មករនិយោជិត។

ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ដើម្បីធានាបានសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ និងលើកកម្ពស់ផលិតភាពការងារ ក្រសួងលើកទឹកចិត្តឱ្យម្ចាស់ ឬនាយករោងចក្រពិភាក្សាជាមួយវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា (CGTI) ឬវិទ្យាស្ថានបណ្តុះបណ្តាលផ្សេងទៀត រៀបចំបណ្តុះបណ្តាលលើមុខជំនាញច្បាប់ពាក់ព័ន្ធនឹងវិស័យការងារ ជំនាញទន់ និងជំនាញបច្ចេកទេសចាំបាច់នានាក្នុងរោងចក្រ ដល់កម្មករនិយោជិត ជាពិសេសថ្នាក់ដឹកនាំរដ្ឋបាល និងប្រធានផ្នែក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖ លោក ខេម ប៊ុនឈាន (០១២ ៤៣៦ ១៤៣) លោក ម៉ាញ ណារិទ្ធ (០៨៧ ៥២៥ ៦៥៦) និងលោក ឌឹម ឧត្តម (០៩២ ២០៨ ៧៩៧)។

ម្ចាស់ ឬនាយករោងចក្រ និងបងប្អូនកម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ត្រូវចូលរួមអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៣
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

សូមទាញយកឯកសារតាម QR Code នេះ
ឬតាម Link នេះ: http://bit.ly/3mmjsuE

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖**
លេខបញ្ជីពាណិជ្ជកម្ម៖..............................................................
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖......................................
លេខគណនីធនាគារ៖..............................................................
អាសយដ្ឋាន៖.......................................................................
ទូរសព្ទលេខ៖..............................................អ៊ីមែល (E-mail)៖..........................................

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន..........នាក់ រយៈពេល.............ថ្ងៃ/ខែ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំ ........................................................................... ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន..........នាក់ (ស្រី ...... នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន..............នាក់ (ស្រី ...... នាក់) រយៈពេល ....... ថ្ងៃ/ខែ ដោយគិតចាប់ពីថ្ងៃទី.........ខែ........ រហូតដល់ថ្ងៃទី.......ខែ.............ឆ្នាំ២០២៣។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន............................................ ដុល្លារអាមេរិក។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២.....

ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

សូមភ្ជាប់មកជាមួយ:
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និងជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- បណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)

## *ឧបសម្ព័ន្ធទី២៖ សេចក្តីណែនាំស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម*

- ចូលទៅកាន់គេហទំព័រ ***https://suspension.mlvt.gov.kh***
- Log in ដោយបំពេញ Username និង Password (យកលេខទូរសព្ទលេខរៀងទី១ នៃបញ្ជីឈ្មោះកម្មករនិយោជិតដែលរោងចក្របានធ្វើបច្ចុប្បន្នភាពមកក្រសួង)

**ជំហានទី ១**

- បំពេញព័ត៌មានដូចជាឈ្មោះរោងចក្រ, អាសយដ្ឋាន......
- ភ្ជាប់ (Upload) ឯកសារជា PDF ឬរូបភាព៖
  - ✓ វិញ្ញាបនបត្រពាណិជ្ជកម្ម
  - ✓ កិច្ចព្រមព្រៀងក្នុងការកំណត់ផ្តល់ និងរបៀបបើកប្រាក់ឧបត្ថម្ភ
  - ✓ វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថានក្នុង ប.ស.ស. (បើមាន)
  - ✓ បណ្ណពន្ធប៉ាតង់
  - ✓ បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ

**ជំហានទី ២**

- បំពេញមូលហេតុនៃការស្នើសុំព្យួរកិច្ចសន្យាការងារ
- បំពេញចំនួនកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ និងរយៈពេលព្យួរកិច្ចសន្យាការងារ

**ជំហានទី ៣**

ជ្រើសរើសព្យួរកម្មករនិយោជិតទាំងអស់ ឬព្យួរមួយចំនួន

**ជំហានទី ៤**

ជ្រើសរើសឈ្មោះកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ ចេញពីបញ្ជីឈ្មោះដែលមានក្នុងប្រព័ន្ធ (ប្រសិនបើព្យួរមួយចំនួន)

**ជំហានទី ៥**

ចុចបញ្ចប់ការស្នើសុំព្យួរកិច្ចសន្យាការងារ

**ជំហានទី ៦**

- ចូលទៅទំព័រដើម ដើម្បី៖
  - ✓ ទាញយកលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ ដើម្បីចុះហត្ថលេខា និងត្រៀមប្រគល់ជូនអធិការការងារពេលចុះពិនិត្យផ្ទៀងផ្ទាត់
  - ✓ ទាញយកបញ្ជីឈ្មោះកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ ដើម្បីយកទៅស្វែងរក និងបំពេញព័ត៌មាន ដូចជាលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, លេខទូរសព្ទ, លេខបណ្ណសមាជិក ប.ស.ស. ...... និងឱ្យកម្មករនិយោជិតផ្តិតមេដៃបញ្ជាក់
- ក្រោយពេលអធិការការងារចុះពិនិត្យ និងមានស្នាមមេដៃត្រឹមត្រូវរបស់កម្មករនិយោជិត ត្រូវផ្ញើបញ្ជីឈ្មោះនេះជា Excel File និង Scan បញ្ជីឈ្មោះដែលបោះត្រា និងមានស្នាមមេដៃនេះជា PDF File មក ***E-mail: suspension@nea.gov.kh***

ព័ត៌មានបន្ថែម៖

លោក លាង សុភ័គ (099 883 358) លោក នុត សីហា (012 881 982) លោក ស៊ុន វាសនា (010 559 899)

*ឧបសម្ព័ន្ធទី៣៖ បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ*

**បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ**

**ក្រុមហ៊ុន**............................................ **សកម្មភាពអាជីវកម្ម** ........................................

**អាសយដ្ឋាន** ..............................................................................................

រយៈពេលព្យួរកិច្ចសន្យាការងារ.............ថ្ងៃ/ខែ ចាប់ពីថ្ងៃទី.......ខែ........ឆ្នាំ២០២..... ដល់ថ្ងៃទី......ខែ.........ឆ្នាំ២០២.....

| ល.រ | ឈ្មោះកម្មករនិយោជិត | ភេទ | ថ្ងៃខែឆ្នាំកំណើត | បម្រើការនៅផ្នែក | លេខសមាជិក ប.ស.ស/ លេខរៀងក្នុងបញ្ជីកម្មករនិយោជិតដែលបានធ្វើបច្ចុប្បន្នភាពមកក្រសួង | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | លេខទូរសព្ទ | ស្នាមមេដៃបញ្ជាក់របស់កម្មករនិយោជិត |
|---|---|---|---|---|---|---|---|---|
| 1 | ហេង កញ្ញា | ស | 30.09.1990 | ផ្នែកដេរ/ផ្នែករដ្ឋបាល | XXXXXXX-XXXXXXX-X | XXXXXXXXX | 0XX-XXXXXX | |
| 2 | | | | | | | | |
| 3 | | | | | | | | |
| 4 | | | | | | | | |

បានបញ្ចប់ត្រឹមលេខរៀងទី....

ថ្ងៃទី ...... ខែ ........ ឆ្នាំ២០២.....

ហត្ថលេខា និងត្រា

ម្ចាស់ ឬនាយក

**សម្គាល់៖**

-ក្រុមហ៊ុនត្រូវបោះត្រានៅគ្រប់ទំព័រលើបញ្ជីឈ្មោះនេះ

-ក្រុមហ៊ុនត្រូវផ្ញើបញ្ជីឈ្មោះនេះជា Excel File និង Scan បញ្ជីឈ្មោះដែលបោះត្រា ជា PDF File មក E-mail: suspension@nea.gov.kh

*ឧបសម្ព័ន្ធទី៤៖ លិខិតជូនដំណឹងពីការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ)*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖**
លេខបញ្ជីពាណិជ្ជកម្ម៖..........................................................................
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖...........................................
លេខគណនីធនាគារ៖...............................................................................
អាសយដ្ឋាន៖.........................................................................................
ទូរសព្ទលេខ៖........................................................ អ៊ីមែល (E-mail)៖.................................................

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ** ៖ ការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ)។
**យោង** ៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ លេខ....... ចុះថ្ងៃទី.........ខែ.............ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំ.................................................................................ដូច្នេះ ក្រុមហ៊ុនយើងខ្ញុំស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) ដល់កម្មករនិយោជិតចំនួន.........................នាក់ (ស្រី......) ក្នុងចំណោមកម្មករនិយោជិតដែលបានសុំព្យួរសរុបចំនួន.............នាក់ (ស្រី......) ចាប់ពីថ្ងៃទី..........ខែ........... ឆ្នាំ២០២៣តទៅ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............. ឆ្នាំ២០២.....
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

សូមភ្ជាប់មកជាមួយ:
- លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) ចំនួន ៣ច្បាប់ និងជា Soft Copy (Ms Excel) ទៅ E-mail: suspension@nca.gov.kh

*ឧបសម្ព័ន្ធទី៥៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ*

**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**
លេខ:.........................គប/អក/អធក.

**ជម្រាបមក**
**លោក/លោកស្រី ម្ចាស់ ឬនាយក**.............................................
**អាសយដ្ឋាន**.......................................................................................................

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។
**យោង** ៖ លិខិតលេខ........... ចុះថ្ងៃទី....... ខែ....... ឆ្នាំ២០២៣។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក/លោកស្រី ម្ចាស់ ឬនាយក ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន........នាក់ (ស្រី......នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប............នាក់ (ស្រី......នាក់) រយៈពេលចំនួន.........ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី..........ខែ.........រហូតដល់ថ្ងៃទី..........ខែ.............ឆ្នាំ២០២៣ ក្នុងនោះ៖

- កម្មករនិយោជិតចំនួន ...... នាក់ (ស្រី ...... នាក់) ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ..... ដុល្លារអាម៉េរិកក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ
- កម្មករនិយោជិតចំនួន ...... នាក់ (ស្រី ...... នាក់) មិនទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់ កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ លោក/លោកស្រី ម្ចាស់ ឬនាយក ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី លោក/លោកស្រី ម្ចាស់ ឬនាយក មានបំណងដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ ហើយ លោក/លោកស្រី ត្រូវទទួលខុសត្រូវបង់ជូសកម្មករនិយោជិតទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរកម្មករនិយោជិត ដែលបានចូលធ្វើការមុនកំណត់ទាំងនេះ។ ក្នុងករណីចាំបាច់ លោក/លោកស្រី អាចស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់បានចំនួន ១លើក។ ករណីលើសពី ១លើក លោក/លោកស្រី ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករនិយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ។

អាស្រ័យដូចនេះ សូម លោក/លោកស្រី ម្ចាស់ ឬនាយក មិទផ្សាយនូវលិខិតនេះ ដើម្បីឱ្យកម្មករនិយោជិតបានជ្រាបគ្រប់ៗគ្នា។

សូម លោក/លោកស្រី ម្ចាស់ ឬនាយក ទទួលនូវសេចក្ដីរាប់អានពីខ្ញុំ។

ថ្ងៃ................ ខែ............... ឆ្នាំ....................ស័ក ព.ស.២៥៦.....
រាជធានីភ្នំពេញ ថ្ងៃទី.............ខែ................ឆ្នាំ២០២.....
**ត.ប. រដ្ឋមន្ត្រី**
**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

ចម្លងជូន:
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី ខេត្ត